# ឯកសារទស្សនៈទាន
# កម្មវិធីពិភាក្សាអំពីការសិក្សាស្រាវជ្រាវ
# ស្តីពី
# "បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិលកម្ពុជា"

**កាលបរិច្ឆេទ៖ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៦**

ម៉ោង៖ ៨.៣០ ព្រឹក ដល់ម៉ោង ១២.០០ ថ្ងៃត្រង់

ទីកន្លែង៖ Anik Palace Hotel

អាសយដ្ឋាន៖ផ្ទះលេខ១៥ ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

ផែនទី៖https://maps.app.goo.gl/3kzCrTtg3KvjB9vM7

## ១.សាវតារ

អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក.) គឺជាអង្គការសមាជិកភាពឈានមុខសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសនៅក្នុងប្រទេសកម្ពុជា។ អង្គការ គ.ស.ក. មានសមាជិក២០០ អង្គការ ដែលធ្វើការងារអភិវឌ្ឍលើវិស័យផ្សេងៗ។ គ.ស.ក. បានដើរតួនាទីជាពិសេសក្នុងនាមជាអ្នកសម្របសម្រួល អ្នកឃ្លាំមើល និងអ្នកតស៊ូមតិ ដើម្បីបរិយាកាសអំណោយផល និងមជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាពសម្រាប់អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានប្រគល់ការងារជូន អង្គការវេទិកាអនាគត ជាទីប្រឹក្សាឯករាជ្យ ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទ "បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិល " ។ ការសិក្សានេះមានគោលបំណងឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងស្តីពីបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នក្នុងចំណោមអង្គការសង្គមស៊ីវិល ព្រមទាំងរវាងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងវិស័យឯកជន។

## ២. គោលបំណង៖

គោលបំណងនៃការសិក្សាស្រាវជ្រាវជាក់លាក់នេះរួមមាន ៖

- ដើម្បីវាយតម្លៃបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅគ្រប់ទិដ្ឋភាពសំខាន់ៗ យល់ដឹងអំពីតម្រូវការបច្ចុប្បន្នរបស់អង្គការសង្គមស៊ីវិល បង្កើតលំហកិច្ចសន្ទនាសម្រាប់អង្គការ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ GPP
23/02/2023 22/02/2028
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

សង្គមស៊ីវិលជាមួយរដ្ឋាភិបាល និងផ្តល់អនុសាសន៍ជាក់លាក់ដើម្បីកែលម្អបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិល ។

- ពិនិត្យមើលយន្តការភាពជាដៃគូរួមបញ្ចូលដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរវិស័យ។ របកគំហើញស្រាវជ្រាវនេះ ជាមូលដ្ឋានក្នុងការទាញសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា។

**៣.សិក្ខាកាមៈ** កិច្ចពិភាក្សានេះរំពឹងថានឹងមានអ្នកចូលរួមមកតំណាងអង្គការសមាជិក និងអង្គការដៃគូចូលរួមកម្មវិធីនេះ។

**៤.ក្រុមការងារសម្របសម្រួល**:

- អ្នកដឹកនាំពិភាក្សាៈ **លោក ជា ដារ៉ា** អ្នកស្រាវជ្រាវនៅអង្គការវេទិកាអនាគត (Future Forum Research Fellow)
- អ្នកកត់ត្រាៈ **កញ្ញា កុច ស្រីមាន** និង **លោក ម៉ុន រិទ្ធី** អ្នកស្រាវជ្រាវនៅអង្គការវេទិកាអនាគត (Future Forum Junior Research Fellows)

**៥.របៀបវារៈ**

| **ពេលវេលា** | **សកម្មភាព** | **អ្នកសម្របសម្រួល** |
|---|---|---|
| ៨:៣០–៨:៤០ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារអង្គការ គ.ស.ក |
| **៨:៤០–៩:០០** | **អាហារសម្រន់ និងកសាងបណ្តាញ** | **អ្នកចូលរួមទាំងអស់គ្នា** |
| ៩:០០–៩:១០ | មតិស្វាគមន៍ និងបង្ហាញអំពីកម្មវិធី និងការណែនាំក្រុមការងារ | ក្រុមការងារស្រាវជ្រាវនៃអង្គការវេទិកាអនាគត |
| ៩:១០–១០:៤០ | កិច្ចពិភាក្សាលើប្រធានបទស្រាវជ្រាវសំខាន់ៗ | ក្រុមការងារស្រាវជ្រាវនៃអង្គការវេទិកាអនាគត |
| ១០:៤០–១១:០០ | ការសង្ខេបចំណុចសំខាន់ៗ និងបូកសរុបកម្មវិធីនៃកិច្ចពិភាក្សា | ក្រុមការងារស្រាវជ្រាវនៃអង្គការវេទិកាអនាគត |
| **១១:០០–១២:០០** | **សម្រាកអាហារថ្ងៃត្រង់រួមគ្នា** | **អ្នកចូលរួមទាំងអស់គ្នា** |

សម្រាប់កិច្ចពិភាក្សាទាំងអស់ត្រូវបានអនុវត្តក្រោម គោលការណ៍ Chatham House Rule។ អត្តសញ្ញាណរបស់អ្នកចូលរួមនឹងត្រូវបានរក្សាទុកជាសម្ងាត់ ហើយរាល់មតិយោបល់នឹងមិនត្រូវបានបញ្ជាក់ជាបុគ្គល ឬ ស្ថាប័នណាមួយក្នុងរបាយការណ៍ចុងក្រោយឡើយ ដើម្បីធានាបាននូវការពិភាក្សាមួយដោយសេរី និងភាពបើកចំហ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability
23/02/2023 GPP 22/02/2028
Symbol of Trust